**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :**............០៧៣/២១............**ក.ប** / ស.ជ.ណា.ខ.ល

# សេចក្តីជូនដំណឹង

## ស្តីពី

## ការធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់កម្មករនិយោជិតរោងចក្រផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប

យោងសេចក្តីប្រកាសព័ត៌មានស្តីពីការដាក់ឱ្យអនុវត្តកម្មវិធី "ជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់" ដើម្បីជួយគាំទ្រគ្រួសារប្រជាពលរដ្ឋដែលមានកម្រិតជីវភាពទាប និងជួបប្រឈមនឹងការលំបាកក្រោយការអនុវត្តវិធានការបិទខ្ទប់ជាលក្ខណៈទ្រង់ទ្រាយធំ និងការផ្តល់ជំនួយសង្គមជាសាច់ប្រាក់សម្រាប់គ្រួសារ ដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ និងគ្រួសារដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាពក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសូមណែនាំដល់ម្ចាស់ ឬនាយករោងចក្រផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប និងកម្មករនិយោជិតទាំងអស់ដូចខាងក្រោម៖

១. ចំពោះម្ចាស់ ឬនាយករោងចក្រ ត្រូវ៖

- ធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់បងប្អូនកម្មករនិយោជិតដែលមាននៅក្នុងបញ្ជីបើកប្រាក់ឈ្នួលប្រចាំខែមីនា ឆ្នាំ២០២១ ជាបន្ទាន់
- ចាត់តាំងបុគ្គលិកចំនួន ២រូប ឱ្យទទួលបន្ទុកផ្នែកវិធានសុខាភិបាល និងវិធានសុវត្ថិភាពនិងសុខភាពការងារ (OSH) នៅក្នុងរោងចក្រ ដើម្បីទទួលខុសត្រូវក្នុងការធ្វើបច្ចុប្បន្នភាពអំពីស្ថានភាពវិជ្ជមានកូវីដ-១៩ និងឈ្មោះគ្រូពេទ្យ ឬគិលានុបដ្ឋាកប្រចាំរោងចក្រជូនក្រសួង ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ផ្តល់បញ្ជីឈ្មោះកម្មករនិយោជិត និងឈ្មោះពេទ្យ ឬគិលានុបដ្ឋាកប្រចាំរោងចក្រជា Excel File (ដូចមានក្នុងឧបសម្ព័ន្ធ) និងស្កេនបញ្ជីឈ្មោះដែលបោះត្រានៅគ្រប់ទំព័រជា PDF File មកប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (https://lacms.mlvt.gov.kh/registration/upload/excel) ឱ្យបានមុន **ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១**។ ម្ចាស់ ឬនាយករោងចក្រ អាចសួរព័ត៌មានបន្ថែមតាមរយៈក្រុមតេឡេក្រាម https://t.me/EmployerChat។

ដើម្បីធានាបាននូវការទទួលខុសត្រូវ និងតម្លាភាពនៃការធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរនេះ ម្ចាស់ ឬនាយករោងចក្រ ត្រូវ៖

- ចាត់ចែងជាលាយលក្ខណ៍អក្សរប្រគល់ភារកិច្ចឱ្យប្រធានក្រុម ឬប្រធានផ្នែកជូនដំណឹងដល់បងប្អូនកម្មករនិយោជិតរបស់ខ្លួនសហការផ្ទៀងផ្ទាត់លេខទូរស័ព្ទ និងលេខអត្តសញ្ញាណប័ណ្ណរបស់ខ្លួនឡើងវិញ
- ស្វែងរកវិធីសាស្ត្រផ្ទៃក្នុង ណែនាំឱ្យបងប្អូនកម្មករនិយោជិតផ្ទៀងផ្ទាត់ និងផ្តិតមេដៃទទួលស្គាល់លេខទូរស័ព្ទ និងលេខអត្តសញ្ញាណប័ណ្ណរបស់ខ្លួនជាពិតជាត្រឹមត្រូវ
- ចាក់ឃ្លីបសំឡេងស្តីពីការជូនដំណឹងនេះ តាមប្រព័ន្ធផ្សព្វផ្សាយផ្ទៃក្នុងរោងចក្ររបស់ខ្លួនឱ្យបានញឹកញាប់ ដើម្បីជូនដំណឹងដល់បងប្អូនកម្មករនិយោជិតឱ្យបានដឹង និងយល់អំពីកាតព្វកិច្ចនៃការធ្វើបច្ចុប្បន្នភាពនេះ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤៣៧៥ និងទូរសារ:(០២៣)៨៨២៧៦៩

- បង្រៀនប្រតិភូបុគ្គលិក និងប្រធានផ្នែកឱ្យជួយប្រាប់ ឬអានលេខទូរស័ព្ទ និងលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដល់បងប្អូនកម្មករនិយោជិតដែលមិនចេះអាន និងសរសេរអក្សរ ដើម្បីធ្វើការផ្ទៀងផ្ទាត់ឈ្មោះ និងលេខទូរស័ព្ទ
- ផ្ញើឈ្មោះកម្មករនិយោជិតដែលមានវិជ្ជមានកូវីដ-១៩ ហើយដែលត្រូវបានព្យាបាលជាសះស្បើយ ដោយមានលិខិតបញ្ជាក់ពីមន្ទីរពេទ្យ ឬមជ្ឈមណ្ឌលព្យាបាលជំងឺកូវីដ-១៩ មក "ប្រព័ន្ធឃ្លាំមើលករណីកូវីដ-១៩ តាមរោងចក្រសហគ្រាស" https://lacms.mlvt.gov.kh/covid-19surveillance របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលនឹងដាក់ឱ្យដំណើរការនៅក្នុងសប្តាហ៍ទី១ នៃខែមិថុនា ឆ្នាំ២០២១ នេះ។

ប្រសិនជាកម្មករនិយោជិតណាម្នាក់ខកខានមិនទទួលបានជំនួយសង្គមជាសាច់ប្រាក់ ដែលការខកខាននេះគឺបណ្តាលមកពីកំហុសរបស់និយោជក នោះម្ចាស់ ឬនាយករោងចក្រ ត្រូវទទួលខុសត្រូវក្នុងការផ្តល់ជំនួយសង្គមជាសាច់ប្រាក់ជូនទៅកម្មករនិយោជិតដោយខ្លួនឯង។ ទន្ទឹមនឹងនេះ ម្ចាស់ ឬនាយករោងចក្រ ក៏អាចត្រូវទទួលពិន័យតាមច្បាប់ស្តីពីការងារ និងច្បាប់ជាធរមានដទៃផ្សេងទៀតផងដែរ។

**២. ចំពោះបងប្អូនកម្មករនិយោជិត ត្រូវៈ**

- ផ្តល់លេខទូរស័ព្ទដែលអាចទំនាក់ទំនងបានចំនួន ១ខ្សែ ទៅអ្នកទទួលបន្ទុករដ្ឋបាលរោងចក្ររបស់ខ្លួន ដើម្បីឱ្យអ្នកទទួលបន្ទុករដ្ឋបាលធ្វើបច្ចុប្បន្នភាពតារាងបញ្ជីឈ្មោះ មកក្រសួងឱ្យបានមុនថ្ងៃទី**២៧ ខែឧសភា ឆ្នាំ២០២១**
- រក្សាលេខទូរស័ព្ទដែលបានផ្តល់ឱ្យរោងចក្រជាដាច់ខាត រហូតដល់ពេលជំងឺកូវីដ-១៩ ត្រូវបានបញ្ចប់
- ទទួលខុសត្រូវខ្លួនឯងចំពោះការខាតបង់ផលប្រយោជន៍ផ្សេងៗ ដែលបណ្តាលមកពីការខកខាន ឬយឺតយ៉ាវក្នុងការផ្តល់លេខទូរស័ព្ទ និងលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទៅឱ្យអ្នកទទួលបន្ទុករដ្ឋបាលរបស់រោងចក្រ
- ទំនាក់ទំនងអ្នកទទួលបន្ទុករដ្ឋបាលរោងចក្រឱ្យផ្ញើឈ្មោះមក "ប្រព័ន្ធឃ្លាំមើលករណីកូវីដ-១៩ តាមរោងចក្រសហគ្រាស" https://lacms.mlvt.gov.kh/covid-19surveillance របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំពោះបងប្អូនកម្មករនិយោជិតដែលមានវិជ្ជមានកូវីដ-១៩ ហើយដែលត្រូវបានព្យាបាលជាសះស្បើយ ដោយមានលិខិតបញ្ជាក់ពីមន្ទីរពេទ្យ មជ្ឈមណ្ឌលព្យាបាលជំងឺកូវីដ-១៩ ឬពេទ្យការងារ
- បងប្អូនកម្មករនិយោជិត អាចសួរព័ត៌មានបន្ថែមតាមរយៈក្រុមតេឡេក្រាម https://t.me/KhmerWorkerChat។

ប្រសិនជាបងប្អូនកម្មករនិយោជិតណាម្នាក់ខកខាន ឬមិនបានផ្តល់លេខទូរស័ព្ទទំនាក់ទំនងបច្ចុប្បន្ន និងលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ទៅឱ្យអ្នកទទួលបន្ទុករដ្ឋបាលរោងចក្ររបស់ខ្លួនតាមកាលកំណត់ នោះបងប្អូនកម្មករនិយោជិតនោះ ត្រូវទទួលខុសត្រូវដោយខ្លួនឯងចំពោះការខកខានមិនទទួលបានជំនួយសង្គមជាសាច់ប្រាក់នេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ម្ចាស់ ឬនាយករោងចក្រផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប និងកម្មករនិយោជិតទាំងអស់ ត្រូវចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ ៣ ៦ ១៣ កើត ខែ ពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូនៈ**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់អង្គភាព និងមន្ទីរនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- សមាគមស្បែកជើងកម្ពុជា

ឧបសម្ព័ន្ធនៃសេចក្តីជូនដំណឹងលេខ: ០២៣/២១ ក.ប/ស.ជ.ណ.ខ.ល ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ ២០២១

**បញ្ជីឈ្មោះកម្មករនិយោជិត និងបុគ្គលិក**

**រោងចក្រ ..............................................................................................................**

**នៅក្នុងបញ្ជីបើកប្រាក់ឈ្នួល នៅក្នុងខែមីនា ឆ្នាំ២០២១**

| ល.រ | ឈ្មោះ | ភេទ | ថ្ងៃខែឆ្នាំកំណើត | លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | លេខប័ណ្ណសមាជិក ប.ស.ស. | សញ្ជាតិ | លេខទូរស័ព្ទ |
|---|---|---|---|---|---|---|---|
| 1 | | | | | | | |
| 2 | | | | | | | |
| 3 | | | | | | | |
| 4 | | | | | | | |
| 5 | | | | | | | |

ថ្ងៃទី ........... ខែ ........ ឆ្នាំ២០២១

ហត្ថលេខា និងត្រា

នាយក ឬម្ចាស់ រោងចក្រ

បានបញ្ចប់ត្រឹមលេខរៀងទី ....

សម្គាល់៖

-រោងចក្រ សហគ្រាស ត្រូវវាយត្រានៅគ្រប់ទំព័រលើបញ្ជីឈ្មោះនេះ

-រោងចក្រ សហគ្រាស ត្រូវផ្ញើបញ្ជីឈ្មោះនេះជា Excel File និងស្កេនបញ្ជីឈ្មោះដែលបោះត្រានៅគ្រប់ទំព័រជា

**PDF File មក https://lacms.mlvt.gov.kh/registration/upload/excel**